**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១៧)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១២ ៤១០នាក់ នៃរោងចក្រ សហគ្រាស ទាំង៤៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីងនឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៤៤ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃ សុក្រ ៦កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២០*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៤៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 30 |
| 1 | ក្រុមហ៊ុនឌី ឡាកស៍ អ៊ិនធើណេសិនណល ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុនប៊ីវី អឹកែវីល (ខេមបូឌា) | ភ្នំពេញ |
| 4 | ក្រុមហ៊ុនឌីអេសអិល2 អេនធើប្រាយ | ភ្នំពេញ |
| 5 | ក្រុមហ៊ុនស៊ីន ឡាន (ខេមបូឌា)ហ្គាមេន ខមភេនី លីមីធីត | ភ្នំពេញ |
| 6 | ក្រុមហ៊ុនឌី&ជេ (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 7 | ក្រុមហ៊ុនសេីង យ៉ុង ហ្គាមែនហ្វាក់តូរី ខូអេលធីឌី | ភ្នំពេញ |
| 8 | ក្រុមហ៊ុនឡុង ឈឹង ស៊ូ ផាត ឯ.ក | កំពង់ចាម |
| 9 | ក្រុមហ៊ុនឝីន ម៉ីង ហ៊ែនប៉ែក (ខេមបូឌា) អ៊ិនដាសស្ទ្រៀល ឯ.ក | កណ្តាល |
| 10 | ក្រុមហ៊ុនអេលីតវីន (ខេមបូឌា) ឯ.ក | កណ្តាល |
| 11 | ក្រុមហ៊ុនវេមហ្វា លេឌើរ ឯ.ក | កណ្តាល |
| 12 | ក្រុមហ៊ុនភីភីអិន ភីសយ អឹថយខូអិលធីឌី | កណ្តាល |
| 13 | ក្រុមហ៊ុនវីងយីង(ខេមបូឌា)ហ្គាមេនហ្វាក់ធើរី អិលធីឌី | កណ្តាល |
| 14 | ក្រុមហ៊ុនឃ្សៃ យ៉ាង ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 15 | ក្រុមហ៊ុនអេមិណិន ហ្គាម៉ិន(ខេមបូឌា) លីមីធីត | កណ្តាល |
| 16 | ក្រុមហ៊ុនញូអាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត | កណ្តាល |
| 17 | ក្រុមហ៊ុនខេមបូឌានស៊ីកនេតឈ័រ ថេកស្ទាយ ឯ ក | ស្វាយរៀង |
| 18 | ក្រុមហ៊ុនយីងម៉េកឃើ(ខេមបូឌា)ហ្វូតវែរ | ស្វាយរៀង |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 19 | ក្រុមហ៊ុនយីង អ៊ីធើណល (ខេមបូឌា) | ស្វាយរៀង |
| 20 | ក្រុមហ៊ុនវ៉ាយ ធី ស៊ី ខបប៉័រេសិន | កំពង់ស្ពឺ |
| 21 | ក្រុមហ៊ុនម៉ូណូភា (ខេមបូឌា) ខូ អិល ធីឌី (1) | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុនម៉ូណូភា (ខេមបូឌា) ខូ អិល ធីឌី (2) | កំពង់ស្ពឺ |
| 23 | ក្រុមហ៊ុនមីង ហ្វៃ អេនធើប្រាយ(ខេមបូឌា)ឯ.ក. | កំពង់ស្ពឺ |
| 24 | ក្រុមហ៊ុនញូខាំមើ ឡាក់ហ្គេដ អេនប៉ែក (ខេមបូឌា) មេនូហ្វេកធីរីង ឯ.ក | កំពង់ស្ពឺ |
| 25 | ក្រុមហ៊ុនហុងកុងវីនហ្វៀរហ្គាមេន(ខេមបូឌា)អិលធីឌី | កំពង់ស្ពឺ |
| 26 | ក្រុមហ៊ុនជីង ហ៊ួយ សែ ព្រីនធីង ឯ.ក | កំពង់ស្ពឺ |
| 27 | ក្រុមហ៊ុនហាធ័រអិនធើណេសិនណល(ខេមបូឌា)ឯ.ក | តាកែវ |
| 28 | ក្រុមហ៊ុនស៊ី ស៊ី អេហ្វ ស៊ូមេនូហ្វេកធើរី | តាកែវ |
| 29 | ក្រុមហ៊ុនដាប់ប៊ែលយូអ៊ីជីស៊ី ម៉ែនញ៉ូហ្វែកធីរីង លីមីតធីត | ព្រះសីហនុ |
| 30 | ក្រុមហ៊ុនខេមបូឌាន សាន់វ៉ាយ ហ្គាមេន ខូអិលធីឌី | ព្រះសីហនុ |
| ខ. វិស័យទេសចរណ៍ | | 14 |
| 31 | ក្រុមហ៊ុនអលខ្មែរ (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 32 | ក្រុមហ៊ុនអូរៀរ ហូថេល (ខេមបូឌា) ឯ. ក | ភ្នំពេញ |
| 33 | ក្រុមហ៊ុនកំបូឌីយ៉ាណា អិនវេស្តមេនធ៍ (ភ្នំពេញ) ភីធីអ៊ី អែលធីឌី | ភ្នំពេញ |
| 34 | ក្រុមហ៊ុនខមមិនអេឿ (ខេមបូឌា) | សៀមរាប |
| 35 | ក្រុមហ៊ុនអេប៉ិច ខេមបូឌា ត្រាវ៉ែល សេវើស | សៀមរាប |
| 36 | ក្រុមហ៊ុនវីត្រូ អិនវេសមេន | សៀមរាប |
| 37 | ក្រុមហ៊ុនអេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 38 | ក្រុមហ៊ុនរ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 39 | សណ្ឋាគារ ស្មាយលីង | សៀមរាប |
| 40 | សណ្ឋាគារតូលែន | សៀមរាប |
| 41 | ក្រុមហ៊ុនអឺបៅអេស៊ា | សៀមរាប |
| 42 | ក្រុមហ៊ុនជី ប៊ីច សៀមរាប ឯ.ក | សៀមរាប |
| 43 | ក្រុមហ៊ុនត្រេល អហ្វ ឥណ្ឌូឆាយណា | សៀមរាប |
| 44 | ក្រុមហ៊ុនយូនៀន ឈៃលែន ហ្គ្រោស ឯ.ក | ព្រះសីហនុ |